**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
**អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់**
**កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ**

# សេចក្តីជូនដំណឹង

## ស្តីពីការប្រើប្រាស់ឈ្មោះអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ និងត្រាមូលរបស់អគ្គនាយកដ្ឋាន

**យោង** ៖ អនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម ។

អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ មានកិត្តិយសសូមគោរពជូនដំណឹង **សម្តេច ឯកឧត្តម លោកជំទាវ** លោក លោកស្រី និងសាធារណៈជនទាំងអស់ មេត្តាជ្រាបថា ៖ អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍ អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ត្រូវបានផ្លាស់ប្តូរឈ្មោះថ្មីទៅជា អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ តាមរយៈអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម ។ ជាមួយគ្នានឹងការផ្លាស់ប្តូរឈ្មោះនេះ ត្រាមូលរបស់អគ្គនាយកដ្ឋាន ក៏ត្រូវបានផ្លាស់ប្តូរថ្មី ដើម្បីឱ្យមានសង្គតិភាពទៅនឹងឈ្មោះថ្មី ។

អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ សូមបង្ហាញជូននូវគំរូត្រាមូលថ្មី ដូចបានគោរពជូនភ្ជាប់មកជាមួយ ព្រមទាំងប្រកាសការប្រើប្រាស់ជាផ្លូវការនូវឈ្មោះ និងត្រាមូលថ្មីរបស់អគ្គនាយកដ្ឋាន ចាប់ពីថ្ងៃនេះតទៅ ។

**គំរូត្រាមូលរបស់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់**
**កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ**



ថ្ងៃពុធ ២កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០